00850930

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 04 / 10 / 2012
ម៉ោង (Time/Heure) : 11:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

លេខ/N°: 5

***តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ***

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៣/២៩-០៧-២០១១-អវតក/អបជ (០១)

ចំពោះមុខ: **ចៅក្រម ប្រាក់ គីមសាន ប្រធាន**
**ចៅក្រម** Rowan DOWNING
**ចៅក្រម នេយ ថុល**
**ចៅក្រម** Chang-Ho CHUNG
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: **ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២**

---

**សាធារណៈ:**
**សេចក្តីសម្រេចលើញត្តិសុំពិចារណាឡើងវិញនូវសេចក្តីសម្រេចលើសំណើរបស់អង្គភាពគាំពារការការពារក្តីសុំផ្អាកដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០៣ នៅចំពោះមុខអង្គបុរេជំនុំជម្រះ និងសុំឲ្យមានវិធានការនាក់ទងនឹងការតំណាងដោយប្រសិទ្ធភាពជូនជនសង្ស័យក្នុងសំណុំរឿង ០០៣**

---

**សហចៅក្រមស៊ើបអង្កេត:**
យូ ប៊ុនឡេង
Laurent KASPER-ANSERMET

**ម្ចាស់សំណើ:**
លោកស្រី Nisha VALABHJI
មន្ត្រីទទួលបន្ទុកផ្នែកគាំពារការការពារក្តី

**០០៣/២៩-០៧-២០១១-អវតក/អបជ (០៦)**

**លេខ/N⁰: ៥**

**សហព្រះរាជអាជ្ញាអន្តរជាតិ**

**ជា លាង**

Andrew CAYLEY

សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖

**សំ សុគង់**

Lyma Thuy NGYEN

**ជួង ជូងី**

**ហុង គីមសួន**

Silke STUDZINSKY

១. **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះសាលាវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានទទួល “ញត្តិសុំពិចារណាឡើងវិញ នូវសេចក្តីសម្រេចលើសំណើរបស់អង្គភាពគាំពារការការពារក្តីសុំផ្អាកដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០៣ នៅចំពោះមុខអង្គបុរេជំនុំជម្រះ និងសុំឱ្យមានវិធានការ ទាក់ទងនឹងការតំណាងដោយប្រសិទ្ធភាពជូនជនសង្ស័យក្នុងសំណុំរឿង ០០៣” (“ញត្តិសុំពិចារណាឡើងវិញ”) ដែលបានដាក់ដោយមន្ត្រីទទួលបន្ទុកអង្គភាព DSS (“ភាគីស្នើសុំ”) នៅក្នុងផ្នែកគាំពារការការពារក្តី (DSS) នៃ អ.វ.ត.ក នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២[១]។ ញត្តិសុំពិចារណាឡើងវិញ ត្រូវបានជូនដំណឹងនៅថ្ងៃទី ៨ ខែ មីនា ឆ្នាំ ២០១២។ ពុំមានការដាក់ចម្លើយតបណាមួយទៅនឹងញត្តិសុំពិចារណាឡើងវិញឡើយ។

## សារណាសុំឱ្យមានការពិចារណាឡើងវិញ

២. ម្ចាស់សំណើបានស្នើឱ្យអង្គបុរេជំនុំជម្រះ “ពិចារណាឡើងវិញនូវសំណើរបស់អង្គភាព DSS ស្តីពីការទទួលយកសំណើនេះ ពិនិត្យមើលហេតុផលសមស្របនៃសំណើរបស់អង្គភាព DSS និងទទួលយកដំណោះស្រាយដែលបានស្នើសុំ”[២]។ ម្ចាស់សំណើលើកឡើងថា ញត្តិសុំពិចារណាឡើងវិញត្រូវបានដាក់ “ដោយមូលហេតុថា លក្ខណវិនិច្ឆ័យពីរដែលត្រូវបានទទួលស្គាល់សម្រាប់ការទទួលយកញត្តិសុំពិចារណាឡើងវិញត្រូវបានបំពេញ: (ក) សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះមានកំហុសនៅក្នុងទិដ្ឋភាពជាច្រើន និង (ខ) សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះបណ្តាលឱ្យមាន

---

[១] ញត្តិសុំពិចារណាឡើងវិញនូវសេចក្តីសម្រេចលើសំណើរបស់អង្គភាពគាំពារការការពារក្តីសុំផ្អាកដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០៣ នៅចំពោះមុខអង្គបុរេជំនុំជម្រះ និងសុំឱ្យមានវិធានការទាក់ទងនឹងការតំណាងដោយប្រសិទ្ធភាពជូនជនសង្ស័យក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារលេខ ៤ (“ញត្តិសុំពិចារណាឡើងវិញ”)។

[២] ញត្តិសុំពិចារណាឡើងវិញ កថាខណ្ឌ ៥១។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER E.C.C.C * C.E.T.C * PRÉLIMINAIRE

ភាពអយុត្តិធម៌”[៣]។ ភាគីស្នើសុំជំទាស់ថា អង្គបុរេជំនុំជម្រះមានការភ័ន្តច្រឡំនៅក្នុងការអនុវត្តលក្ខខណ្ឌតម្រូវអំពីភាពអាចទទួលយកបានដែលញត្តិនានាត្រូវ “តែបានលើកឡើងយ៉ាងសមរម្យ” អំពីលក្ខខណ្ឌតម្រូវណាមួយដែល ម្ចាស់សំណើយល់ឃើញថា “បានកំណត់មិនត្រឹមត្រូវ”[៤] និង លើកឡើងថា “នៅ អ.វ.ត.ក ដែលគ្រប់គ្រងដោយបទបញ្ញត្តិរបស់តុលាការនេះផ្ទាល់ ដែលស្រដៀងទៅនឹងបទប្បញ្ញត្តិដែលមានចែងក្នុង សេចក្តីបង្គាប់របស់តុលាការ ICTY ដែរនោះ អំណាចក្នុងការចាត់តាំងមេធាវី គឺស្ថិតនៅលើមន្ត្រីទទួលបន្ទុករបស់អង្គភាព DSS ដោយផ្អែកលើវិធាន ១១(៦) នៃវិធានផ្ទៃក្នុង និងស្របតាមបទបញ្ជារដ្ឋបាលរបស់អង្គភាព DSS”[៥]។ ម្ចាស់សំណើលើកឡើងថែមទៀតថា អង្គបុរេជំនុំជម្រះមានការភ័ន្តច្រឡំនៅក្នុងការវិភាគ និងសន្និដ្ឋានថា បញ្ហានៃការតំណាងផ្លូវច្បាប់ជាការទទួលខុសត្រូវផ្ទាល់របស់សហចៅក្រមស៊ើបអង្កេត និងមិនស្ថិតនៅក្នុងយុត្តាធិការរបស់អង្គបុរេជំនុំជម្រះទេ[៦]។ ញត្តិសន្និដ្ឋានថា “ការខកខានមិនអនុវត្តយុត្តាធិការនេះ អង្គបុរេជំនុំជម្រះបានរំលោភសិទ្ធិរបស់ជនសង្ស័យ ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌”[៧]។

## លក្ខណៈវិនិច្ឆ័យផ្លូវច្បាប់សុំពិចារណាឡើងវិញ

៣. នៅក្នុងយុត្តិសាស្ត្រកាលពីមុនរបស់ខ្លួន អង្គបុរេជំនុំជម្រះបានអនុវត្តលក្ខណៈវិនិច្ឆ័យខាងក្រោមសម្រាប់ការពិចារណាឡើងវិញ៖

---

[៣] ញត្តិសុំពិចារណាឡើងវិញ កថាខណ្ឌ ៣។

[៤] ញត្តិសុំពិចារណាឡើងវិញ កថាខណ្ឌ ១២ ដល់ ១៨។

[៥] ញត្តិសុំពិចារណាឡើងវិញ កថាខណ្ឌ ៥៥។

[៦] ញត្តិសុំពិចារណាឡើងវិញ កថាខណ្ឌ ១៩ ដល់ ៥៥។

[៧] ញត្តិសុំពិចារណាឡើងវិញ កថាខណ្ឌ ៥0 និងកថាខណ្ឌ ៥៦ ដល់ ៥0។

"២៥. ពាក្យសុំពិចារណាឡើងវិញអាចទទួលយកបាន ប្រសិនបើមានមូលដ្ឋានស្របច្បាប់ ដាក់ជូនអង្គបុរេជំនុំជម្រះ ដើម្បីធ្វើការពិចារណាឡើងវិញអំពីសេចក្តីសម្រេចកាលពីលើកមុនរបស់ខ្លួន[៨]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានសម្រេចថា អង្គជំនុំជម្រះ ជាដរាប អាច "ពិចារណាសេចក្តីសម្រេចដែលខ្លួនបានចេញកាលពីលើកមុនសារជាថ្មី តែការពិចារណាសារជាថ្មីនេះ មិនមែនដោយសារមានកាលៈទេសៈប្រែប្រួលប៉ុណ្ណោះទេ គឺអាចដោយសារនៅពេលដែលខ្លួនយល់ឃើញថា សេចក្តីសម្រេចលើកមុនមានកំហុស ឬបណ្តាលឱ្យមានភាពអយុត្តិធម៌"[៩]។ អំណាចនេះអាចពណ៌នាថា ជាអំណាចឆន្ទានុសិទ្ធិ[១០] ហើយជាពិសេស អំណាចនេះជាជម្រើសចុងក្រោយដែលមានភាពចាំបាច់សម្រាប់ស្ថាប័នតុលាការដូចអង្គបុរេជំនុំជម្រះនេះ។ ការផ្លាស់ប្តូរកាលៈទេសៈអាចរួមបញ្ចូលអង្គហេតុថ្មី ឬអំណះអំណាងថ្មី[១១]។ បទដ្ឋានចំពោះការពិចារណាសារជាថ្មីត្រូវបានពណ៌នា ដូចតទៅ: "អង្គជំនុំជម្រះមានអំណាចឆន្ទានុសិទ្ធិដោយឯកឯងក្នុងការពិចារណា សេចក្តីសម្រេចបន្ទាន់បន្ទំដែលបានចេញកាលពីលើកមុន

---

[៨] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Milosevic* សំណុំរឿង IT-02-54-T "សេចក្តីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញាសុំពិចារណាឡើងវិញពាក់ព័ន្ធនឹងសាក្សីរបស់មេធាវីការពារក្តី Mitar Balevic, Vladislav Jovanovic, Vukasin Andric និង Dobre Aleksovski" ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៥ កថាខណ្ឌ ៦។

[៩] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Galic* សំណុំរឿង IT-98-29-AR73 "សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំអនុញ្ញាតប្តឹងសាទុក្ខ" ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០១ កថាខណ្ឌ ១៣ និងរឿងក្តី រដ្ឋអាជ្ញា តទល់នឹង Mucic et al, សំណុំរឿង IT-96-21-Abis "សាលដីកាលើបណ្តឹងសាទុក្ខស្តីពីការប្រកាសទោស" ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០០៣ កថាខណ្ឌ ៤៩។

[១០] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Galic* សំណុំរឿង IT-98-29-A "សេចក្តីសម្រេចលើសំណើសុំពិចារណាឡើងវិញរបស់មេធាវីការពារក្តី" ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៦ ទំព័រ ២។

[១១] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Galic* សំណុំរឿង IT-98-29-A "សេចក្តីសម្រេចលើសំណើសុំពិចារណាឡើងវិញរបស់មេធាវីការពារក្តី" ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៦ ទំព័រ ២។

នៅក្នុងករណីពិសេស "ប្រសិនបើមានកំហុសចំពោះអំណះអំណាងច្បាស់លាស់ ឬ ប្រសិនបើចាំបាច់ក្នុងការរារាំងកុំឲ្យមានភាពអយុត្តិធម៌"[១២]"[១៣]។

## សេចក្តីសង្ខេបនានារបស់អង្គបុរេជំនុំជម្រះ

៤. នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើសំណើរបស់អង្គភាពគាំពារការការពារក្តី សុំផ្អាកដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០៣ (សេចក្តីសម្រេច)[១៤] អង្គបុរេជំនុំជម្រះបានសម្រេចថា សំណើនេះពុំអាចទទួលយកបានឡើយ។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា ពាក្យសុំ ឬ សំណើទាំងនេះ ដែលត្រូវបានដាក់ នៅចំពោះមុខអង្គបុរេជំនុំជម្រះ ត្រូវតែ "លើកឡើងឲ្យបានសមរម្យ" ហើយសំណើសុំផ្អាកដំណើរការនីតិវិធី សំដៅជាចំបងលើ "ក្រុមមេធាវីការពារក្តី"[១៥] ដែលពាក្យនេះត្រូវបានគេសរសេរថាជា "អង្គភាពគាំពារការការពារក្តី" ពោលគឺពុំមែន "មេធាវីតំណាងជនណាម្នាក់នៅចំពោះមុខ អ.វ.ត.ក ឡើយ"។ មិនតែប៉ុណ្ណោះ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ទៀតថា អង្គភាពគាំពារការការពារក្តី គឺជាការិយាល័យមួយនៃការិយាល័យរដ្ឋបាលដែល "ជួយអង្គជំនុំជម្រះ

---

[១២] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Milutinovic et al,* សំណុំរឿង IT-05-87-T "សេចក្តីសម្រេចលើសំណើសុំរបស់រដ្ឋអាជ្ញាសុំចាត់វិធានការការពារពាក់ព័ន្ធនឹងការជំនុំជម្រះក្តីបន្ថែមសម្រាប់សាក្សី K56" ចុះថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ទំព័រ ២។

[១៣] សេចក្តីសម្រេចលើសំណើសុំពិចារណាឡើងវិញអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការលើកឡើងជូនអង្គបុរេជំនុំជម្រះដោយផ្ទាល់ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៨ ឯកសារ C22/I/68 កថាខណ្ឌ ២៥ (លើងទំព័រមិនត្រូវបានលុបចោលទេដើម្បីជាឯកសារយោង)។

[១៤] សេចក្តីសម្រេចលើសំណើរបស់អង្គភាពគាំពារការការពារក្តីសុំផ្អាកដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះ និងសុំឲ្យមានវិធានការទាក់ទងនឹងការតំណាងប្រកបដោយប្រសិទ្ធភាពជូនជនសង្ស័យក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារលេខ ៣ ("សេចក្តីសម្រេច")។

[១៥] សេចក្តីសម្រេច កថាខណ្ឌ ៩។

"បំពេញបេសកកម្មការងាររបស់ខ្លួន"[១៦]។ សេចក្ដីសង្កេតទាំងនេះរបស់អង្គបុរេជំនុំជម្រះ មានលក្ខណៈគ្រប់គ្រាន់សមល្មមអាចឱ្យអ្នកអានសាមញ្ញម្នាក់ ដែលពុំមែនជាមេធាវីយល់បានថា បញ្ហាថាតើតំណាងអង្គភាពជាក់លាក់ណាមួយនៅក្នុងការិយាល័យរដ្ឋបាលរបស់តុលាការ មាន ឬ ពុំមានសិទ្ធិ[១៧] ដូចជាសិទ្ធិបង្ហាញខ្លួន ឬ សិទ្ធិដាក់ពាក្យសុំនៅចំពោះមុខអង្គជំនុំជម្រះដើម្បីស្នើសុំឱ្យដោះស្រាយ នៅក្នុងកិច្ចដំណើរការនីតិវិធីដែលខ្លួនពុំមែនជាភាគី។ បញ្ហានេះជាបញ្ហាមួយក្នុងចំណោមបញ្ហាទាំងឡាយសម្រាប់យកមកធ្វើការវាយតម្លៃលើការទទួល ឬ ពុំទទួលពាក្យសុំនានាមុនពេលឈានចូលពិនិត្យអង្គសេចក្ដីនៃពាក្យសុំណាមួយនោះ។ បញ្ហាសិទ្ធិ ឬ ករណីថាតើពាក្យសុំ

---

[១៦] សេចក្ដីសម្រេច កថាខណ្ឌ ១១ និងលេខយោងជើងទំព័រ ២៤។

[១៧] អង្គភាពគាំពារការការពារក្ដីពុំមែនជា "ភាគី" នៃរឿងក្ដី ឬ នៃកិច្ចដំណើរការនីតិវិធីណាមួយនៅចំពោះមុខ អ.វ.ត.ក យោងតាមអត្ថន័យនៃពាក្យពេចន៍ដូចបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមនៃវិធានផ្ទៃក្នុង។ អង្គភាពគាំពារការការពារក្ដីពុំមែនតំណាងភាគីណាមួយនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ផងដែរ។ *សូមមើល* STL សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខប្រឆាំងនឹងដីកាសម្រេចរបស់ចៅក្រមអង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងយុត្តាធិការ និងសិទ្ធិ CH/AC/2010/02 អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ កថាខណ្ឌ ៦០ ដែលចែងថា៖ "សិទ្ធិ ដែលជាគោលការណ៍ទូទៅ "គឺជាសិទ្ធិរបស់ជនម្នាក់ដែលទទួលរងដូចបានចោទប្រកាន់ទៅនឹងការរំលោភវិធានគតិយុត្ត ស្នើសុំឱ្យផ្ដល់សំណងចំពោះការខូចខាតដែលជននេះអាចទទួលរង"។ *កត់សម្គាល់ថា ជនទាំងឡាយពុំមានសិទ្ធិ ពោលគឺ សិទ្ធិស្នើសុំសំណងចំពោះការខូចខាតនៅក្នុងកិច្ចដំណើរការនីតិវិធី ដែលខ្លួនពុំមែនជាភាគី សូមមើល* រឿងក្ដី Ntabakuze ទល់នឹង រដ្ឋអាជ្ញា ICTR-98-41-AR73 សេចក្ដីសម្រេចលើញត្តិសុំឱ្យពិចារណាឡើងវិញ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ៤ ខែ តុលា ឆ្នាំ ២០០៦ កថាខណ្ឌ ១៤-១៥។ រដ្ឋអាជ្ញា ទល់នឹង Delić IT-04-83-A សេចក្ដីសម្រេចលើញត្តិសុំឱ្យបន្តកិច្ចដំណើរការនីតិវិធីតុលាការកំពូល អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១០ ទំព័រ ២។ រដ្ឋអាជ្ញា ទល់នឹង Brima et al. SCSL-04-16-AR77 សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរួមរបស់ក្រុមមេធាវីការពារក្ដីប្រឆាំងនឹងសេចក្ដីសម្រេចលើរបាយការណ៍របស់ក្រុមអ្នកច្បាប់ឯករាជ្យ អនុលោមតាមវិធាន ៧៧(គ)(iii) និង ៧៧ (ឃ) អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៥ កថាខណ្ឌ ១៦។ រដ្ឋអាជ្ញា ទល់នឹង Brima et al. SCSL-04-16-AR77 សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរួម អនុលោមតាមវិធាន ៧៧(ញ)(iii) លើការដាក់វិធានការបណ្ដោះអាសន្ន និងដីកាសម្រេច អនុលោមតាវិធាន ៧៧(គ)(iii) អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៥ កថាខណ្ឌ ៣៣-៣៥។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C.

មួយត្រូវបានលើកឡើងត្រឹមត្រូវដែរ ឬយ៉ាងណានោះ ត្រូវបានអង្គបុរេជំនុំជម្រះយកមកពិចារណា នាពេលមុនរួចហើយ[១៨] ហើយវាក៏ជាផ្នែកមួយនៃយុត្តិសាស្ត្ររបស់សាលាក្តីអន្តរជាតិផ្សេងទៀតផងដែរ[១៩] នៅពេលសាលាក្តីទាំងនេះធ្វើការពិនិត្យលើភាពអាចទទួលយកបាននៃពាក្យសុំមុនពេល

---

[១៨] សំណុំរឿង ០០២/០៧-១២-២០០៩-អវតក-/អបជ (០៥) សាលដីកាលើពាក្យបណ្តឹងតាមវិធានផ្ទៃក្នុង ៣៤ របស់លោក អៀង សារី និងលោកស្រី អៀង ធីរិទ្ធ ប្តឹងជំទាស់ចៅក្រម Marcel Lemonde ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ២០។ សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក-/កសចស (អបជ ៤៧ និង ៤៨) សាលដីកាលើបណ្តឹងឧទ្ធរណ៍លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ និងដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឯកសារលេខ D250/3/2/1/5 ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១០ កថាខណ្ឌ ១៧។ សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក-/កសចស (អបជ ៥៧) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចំពោះដីកាសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរ ទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន ឯកសារលេខ D195/5/5 ចុះថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០១០ កថាខណ្ឌ ១៥-១៦។ ពាក្យសុំលេខ ០០២/០៨-០៧-២០០៩-អវតក/អបជ សាលដីកាលើបណ្តឹងជំទាស់របស់ជនត្រូវចោទទៅលើលោកបណ្ឌិត Stephen Heder និងលោកបណ្ឌិត David Boyle ឯកសារលេខ ៣ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៩ កថាខណ្ឌ ២០ កថាខណ្ឌ ២២។

[១៩] សាលាក្តីពិសេសសម្រាប់ប្រទេសលីបង់ (STL) សាលដីកាលើបណ្តឹងសាទុក្ខប្រឆាំងនឹងដីកាសម្រេចរបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងយុត្តាធិការ និងសិទ្ធិ CH/AC/2010/02 អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ កថាខណ្ឌ ៥៥។ *រដ្ឋអាជ្ញា ទល់នឹង* Tadić IT-94-1 នៅក្នុងរឿងក្តី សាលដីកា Dragan Opaćić លើពាក្យសុំការអនុញ្ញាតដាក់បណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូល ទំព័រ ២ (កត់សម្គាល់ឃើញថា សេចក្តីលើបញ្ហាដែលផ្អែកលើសិទ្ធិ ទំនងជា "ហួសពីច្បាប់ដីកាសម្រេចផ្សេងៗនឹងបើឱ្យអ្នកដែលពុំមែនជាភាគីដាក់បណ្តឹងសាទុក្ខទៅសាលាក្តី រៀបរាប់ការឈឺចាប់...ករណីនេះមិនអាចនោះទេ"។ រដ្ឋអាជ្ញា ទល់នឹង Brima et al. SCSL-04-16-AR77 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរួមរបស់ក្រុមមេធាវីការពារក្តីប្រឆាំងនឹងសេចក្តីសម្រេចលើរបាយការណ៍របស់ក្រុមអ្នកច្បាប់ឯករាជ្យ អនុលោមតាមវិធាន ៧៧(គ)(iii) និង ៧៧ (ឃ) អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៥។ ដីកាសម្រេចពាក់ព័ន្ធនឹងយុត្តាធិការសាលាក្តីលើវិធានស្តីពីពាក្យសុំរបស់លោក El Sayed ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១០ និងករណីថាតើលោក El Sayed មានសិទ្ធិនៅចំពោះមុខសាលាក្តីនេះដែរឬទេ STL ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១០ CH/PTJ/2010/005។ រដ្ឋអាជ្ញា ទល់នឹង Kordic et al. IT-95-14/2 "សេចក្តីសម្រេចលើកឡើងហេតុផលនៃដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១ ខែ មិថុនាឆ្នាំ ១៩៩៩ ប្រាន

ចូលដល់ការពិចារណាលើអង្គសេចក្ដី។ សេចក្ដីសម្រេចជាច្រើននៅក្នុងឯកសារសំអាងផ្លូវច្បាប់នានាដែលអនុវត្តវិធីសាស្ត្រដូចគ្នា ក្រៅពីវិធីសាស្ត្ររបស់អង្គជំនុំជម្រះនេះឃើញថាមានច្រើនលើសលប់។

៩. នៅថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៥ អង្គជំនុំជម្រះសាលាដំបូងទី I នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា (តុលាការ ICTR) បានលើកឡើងបញ្ហាសិទ្ធិនេះ ថាជាផ្នែកមួយនៃបញ្ហាលើភាពអាចទទួលយកបាន "នៅមុនពេលចូលដល់ការពិចារណាលើអង្គសេចក្ដីនៃពាក្យសុំ"[២០]។

---

ចោលញត្តិរបស់ក្រុមមេធាវីការពារក្ដីសុំពិនិត្យភស្តុតាង" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៩។ រដ្ឋអាជ្ញា ទល់នឹង Bobetko IT-02-62-AR54bis & IT-02-62-AR108bis "សាលដីកាលើការតវ៉ារបស់ក្រូអាត ប្រឆាំងនឹងសេចក្ដីសម្រេច និងដីកាបញ្ជាក់លើចៅក្រម" អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០០ កថាខណ្ឌ ១០-១២។ ស្ថានភាពនៅក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ ICC-01/04 "សាលដីកាលើពាក្យសុំការអនុញ្ញាតដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចលើសំណើសុំ OPCV" អង្គបុរេជំនុំជម្រះទី I ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨ កថាខណ្ឌចុងក្រោយ។ រដ្ឋអាជ្ញា ទល់នឹង Ndayambaje et al ICTR-98-42-AR73 "សាលដីកាលើបណ្ដឹងសាទុក្ខរបស់ Joseph Kanyabashi ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទី II ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៧ ពាក់ព័ន្ធនឹងការច្រានចោលញត្តិសុំផ្ទៀងផ្ទាត់បញ្ជីសាក្សី" អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៧ កថាខណ្ឌ ១៤ ដាក់បណ្ដឹងនេះឡើងវិញនៅក្នុងរឿងក្ដី រដ្ឋអាជ្ញា ទល់នឹង Nyiramasuhuko et al រឿងក្ដីលេខ ICTR-97-21-T និងរឿងក្ដី រដ្ឋអាជ្ញា ទល់នឹង Kanyabashi រឿងក្ដីលេខ ICTR-96-15-T រឿងក្ដីរួមលេខ ICTR-98-42-T "សេចក្ដីសម្រេចលើញត្តិរបស់ Nyiramasuhuko et al សុំបញ្ជាក់លើការដាក់បណ្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៧ និងញត្តិរបស់ Ntahobali សុំបញ្ជាក់លើការដាក់បណ្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៧ និងថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧" អង្គជំនុំជម្រះសាលាដំបូងទី II ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ កថាខណ្ឌ ៩៤។

[២០] រដ្ឋអាជ្ញា ទល់នឹង Bagosora et al. ICTR-98-41-T "សេចក្ដីសម្រេចលើញត្តិរបស់ក្រុមមេធាវីការពារក្ដីសុំផ្ដល់សិទ្ធិដល់ Jean Yaovi Degli ជាមេធាវីនាំមុខសម្រាប់ Gratien Kabiligi ឡើងវិញ" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៥ កថាខណ្ឌ ២៣។

00850939

០០៣/២៩-០៧-២០១១-អវតក/អបជ (០១)

លេខ/N⁰: ៥

៦. លើសពីនេះ នៅថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៥ ក្រោយពីបានពិនិត្យ និងរកឃើញថា ម្ចាស់បណ្តឹងឧទ្ធរណ៍ពុំមានសិទ្ធិនោះ ទើបអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន (តុលាការ SCSL) បានបន្តកត់សម្គាល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះ "ពុំមានសុពលភាពទេ"។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នេះបានកត់សម្គាល់ឃើញថា៖

> "បណ្តឹងឧទ្ធរណ៍ នេះត្រូវបានជនជាប់ចោទចំនួន ៣ រូប នៅក្នុងការជំនុំជម្រះ AFRC ដាក់ប្តឹង ដោយពុំបានសុំការអនុញ្ញាត។ ជនជាប់ចោទទាំង ៣ រូបនេះ ពុំមែនជាកម្មវត្ថុនៃការស៊ើបអង្កេតលើការប្រមាថតុលាការ តាមការបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងឡើយ។ *មេធាវីរបស់ជនជាប់ចោទទាំងនេះពុំត្រូវបានចាត់តាំង* ឱ្យតំណាងការពារបទល្មើសណាមួយក្នុងចំណោមបទល្មើសប្រមាថតុលាការដូចបានចោទប្រកាន់ឡើយ ហើយមេធាវីទាំងនេះក៏ពុំទំនងជាទទួលការណែនាំឱ្យតំណាងការពារជនជាប់ចោទផងដែរ។ យោងតាមចំណុចនេះ ជនជាប់ចោទទាំងនេះ ទោះក្នុងករណីណាក៏ដោយពុំមាន*សិទ្ធិ*ធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចចំនួន ២ របស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹង ១) សំអាងហេតុជឿជាក់ថា ការប្រមាថតុលាការត្រូវបានប្រព្រឹត្តឡើងដោយជនជាប់ចោទផ្សេង ឬ ២) អនុម័តសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការស៊ើបអង្កេតដោយឯករាជ្យលើការប្រមាថតុលាការដូចបានចោទប្រកាន់"[២១]។

៧. អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ SCSL បានកត់សម្គាល់បន្ថែមទៀតថា៖

"អង្គជំនុំជម្រះពុំចាំបាច់ពិចារណាថាតើម្ចាស់បណ្តឹងឧទ្ធរណ៍ មាន ឬ ពុំមាន*សិទ្ធិ*ធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនេះ *ដែលពុំប៉ះពាល់ដោយផ្ទាល់លើពួកគេនោះទេ*។ នេះជាចំណុចពិចារណាមួយ ក្នុងចំណោមចំណុចពិចារណានានា ដែលអង្គជំនុំជម្រះសាលាដំបូងគួរធ្វើដូច្នេះ ប្រសិនបើមាន

---

[២១] រឿងក្តី *ព្រះរាជអាជ្ញា ទល់នឹង* Birma et al រឿងក្តីលេខ SCSL-04-16-AR77 "សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ របស់ក្រុមមេធាវីការពារក្តី អនុលោមតាមវិធាន ៧៧ (ញ) ប្រឆាំងនឹងការដាក់វិធានការបណ្តោះអាសន្ន និងដីកាសម្រេច អនុលោមតាមវិធាន ៧៧ (គ)(iii)" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៥ កថាខណ្ឌ ៣៣។



E.C.C.C ★ C.E.T.C — TRIAL CHAMBER — CHAMBRE

ការសុំការអនុញ្ញាតធ្វើបណ្តឹងនោះ។ វាជាការគួរឱ្យចាប់អារម្មណ៍មួយ ដែលបុគ្គលប៉ះពាល់ដោយផ្ទាល់ ដោយសារដីកាសម្រេចបណ្តោះអាសន្ននេះ ពុំបានដាក់បណ្តឹងប្តឹងនឹងដីកាសម្រេចទាំងនេះ។ យើងចាត់ទុកថាដូច្នេះ ក៏ប៉ុន្តែដើម្បីពិចារណាលើបណ្តឹងឧទ្ធរណ៍នេះ វាគ្រប់គ្រាន់អាចឱ្យយើងយល់ថា បណ្តឹងឧទ្ធរណ៍ ដែលបានដាក់ប្តឹងដោយពុំសុំការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង គឺជាបណ្តឹងដែល *ពុំមានសុពលភាព*[២២]។

៨. នៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះទី II នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (តុលាការ ICC) បានលើកឡើងថា៖

> "ក្នុងករណីដែលអង្គជំនុំជម្រះបានរកឃើញថា បុគ្គលធ្វើបណ្តឹង *ពុំមានសិទ្ធិផ្នែកនីតិវិធី* នៅចំពោះមុខតុលាការអង្គជំនុំជម្រះជាមូលដ្ឋាន *មិនគួរពិនិត្យលើអង្គសេចក្តី* នៃបណ្តឹងនោះទេ លើកលែងតែក្នុងករណីពិសេសដែលវាចាំបាច់ធានានូវ ដូចជាការបញ្ជាក់បំភ្លឺសម្រាប់ពេលខាងមុខឱ្យបានច្បាស់ ការសន្សំសំចៃផ្នែកតុលាការ និងការពន្លឿនកិច្ចដំណើរការនីតិវិធីតែប៉ុណ្ណោះ"[២៣]។

៩. នៅថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះទី II នៃតុលាការ ICC បានយកបណ្តឹងរបស់មេធាវីការពារក្តីមកពិនិត្យ តែនៅក្រោយពេលរកឃើញថា មេធាវីការពារក្តីមានសិទ្ធិធ្វើបណ្តឹង *ប៉ុណ្ណោះ*។ អង្គបុរេជំនុំជម្រះទី II នេះបានលើកឡើងថា៖

---

[២២] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Birma et al រឿងក្តីលេខ SCSL-04-16-AR77 "សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ របស់ក្រុមមេធាវីការពារក្តី អនុលោមតាមវិធាន ៧៧ (ញ) ប្រឆាំងនឹងការដាក់វិធានការបណ្តោះអាសន្ន និងដីកាសម្រេច អនុលោមតាមវិធាន ៧៧ (គ)(iii)" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៥ កថាខណ្ឌ ៣៦។

[២៣] ស្ថានភាពនៅសាធារណរដ្ឋកេនយ៉ា សំណុំរឿង ICC-01-09 "សេចក្តីសម្រេចលើពាក្យសុំអនុញ្ញាតចូលរួមតាមមាត្រា ៥៨, ៥២(៥), (៧)ដល់(៨)(ក) នៃលក្ខន្តិកៈទីក្រុងរ៉ូម និងវិធាន ៣៤(១) និង (២) នៃវិធាននីតិវិធី និងភស្តុតាង" អង្គបុរេជំនុំជម្រះ II ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ៧។

00850941



"ជាមួយនឹងសេចក្តីសម្រេចនាថ្ងៃទី ៨ ខែ មីនា ឆ្នាំ ២០១១ កិច្ចដំណើរការនីតិវិធី បានឆ្លងកាត់មាត្រា ៥៨ ហើយបុគ្គល *ដែលត្រូវបានកោះហៅឱ្យចូលខ្លួននៅចំពោះមុខតុលាការបានទទួលសិទ្ធិផ្នែកនីតិវិធីនៅចំពោះមុខតុលាការ*។ អាស្រ័យហេតុនេះ *នៅក្នុងដំណាក់កាលនេះ ជនសង្ស័យត្រូវគោរពលើសិទ្ធិ និងកាតព្វកិច្ចដែលមានចែងនៅក្នុងច្បាប់*។ ចៅក្រមទោលក៏បានដឹងអំពីពាក្យពេចន៍នៃវិធាន ១២១(១) នៃវិធានដែលចែងថា *ជនសង្ស័យដែលត្រូវបានកោះហៅ ត្រូវទទួលបានសិទ្ធិទាំងឡាយដូចមានចែងនៅក្នុងមាត្រា ៦៧ នៃលក្ខន្តិកៈ* ដែលអាចយល់ដោយត្រង់ៗថា សិទ្ធិទាំងនេះនឹងយកមកអនុវត្តតែនៅក្នុងពេលជនសង្ស័យ *បង្ហាញខ្លួនជាលើកដំបូង*នៅចំពោះមុខអង្គបុរេជំនុំជម្រះតែប៉ុណ្ណោះ។ ទោះបីជាយ៉ាងនេះក្តី ចៅក្រមទោលដែលបានជឿជាក់លើគោលការណ៍ដែលបានពិចារណានៅក្នុងចំណុចខាងលើ សូមរំឭកឡើងវិញអំពីមាត្រា ២១(៣) នៃលក្ខន្តិកៈដែលណែនាំថា ការបកស្រាយ និងការអនុវត្តច្បាប់ត្រូវស្របគ្នាជាមួយនឹងសិទ្ធិមនុស្សទាំងឡាយ ដែលបានទទួលស្គាល់ជាអន្តរជាតិ។ ដោយពិចារណាលើចំណុចនេះ ចៅក្រមទោលបានគោរពតាមយុត្តិសាស្ត្រដែលមានស្រាប់ ជាពិសេសយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប ត្រង់មាត្រា ៦ នៃអនុសញ្ញាស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។ ហេតុដូច្នេះ ចៅក្រមទោលរូបនេះ បានសន្និដ្ឋានថា *សិទ្ធិទាំងនេះដែលបានចែងធានា នៅក្នុងមាត្រា ៦៧ នៃលក្ខន្តិកៈ* រួមទាំងសិទ្ធិទទួលបានសវនាការជំនុំជម្រះ *ត្រូវអនុវត្តភ្លាមៗនៅពេលអង្គជំនុំជម្រះបានចេញដីកាកោះហៅឱ្យបង្ហាញខ្លួន* អនុលោមតាមមាត្រា ៥៨(៧)នៃលក្ខន្តិកៈ"[២៤]។

១០. នៅថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះទី II នៃតុលាការ ICC បានច្រានចោលសំណើសុំ ក្រោយពីខ្លួនបានរកឃើញថា ម្ចាស់សំណើពុំមានសិទ្ធិធ្វើសំណើ[២៥]។

---

[២៤] ស្ថានភាពនៅសាធារណរដ្ឋកេនយ៉ា នៅក្នុងរឿងក្តី រដ្ឋអាជ្ញា តទល់នឹង Ruto et al, សំណុំរឿង ICC-01/09-02-11 "សេចក្តីសម្រេចលើការផ្លាស់ប្តូរលក្ខខណ្ឌនៃការកោះហៅ" អង្គបុរេជំនុំជម្រះ II ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ១១។

[២៥] ស្ថានភាពនៅសាធារណរដ្ឋកេនយ៉ា នៅក្នុងរឿងក្តី រដ្ឋអាជ្ញា តទល់នឹង Ruto et al, សំណុំរឿង ICC-01/09-01-11 "សេចក្តីសម្រេចលើ "សំណើធ្វើឡើងដោយរដ្ឋាភិបាលកេនយ៉ាទាក់ទិននឹងការអះអាងអំពីកិច្ចដំណើរការនីតិវិធីចោទប្រកាន់" អង្គបុរេជំនុំជម្រះ II ចុះថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ៨។

១១. បើទោះជាសេចក្តីសង្កេតរបស់អង្គបុរេជំនុំជម្រះគឺជាប់ពាក់ព័ន្ធនឹងបញ្ហាសិទ្ធិនេះ ដូចបានចង្អុលបញ្ជាក់យ៉ាងត្រឹមត្រូវដោយម្ចាស់សំណើក៏ដោយ ក៏ប៉ុន្តែក្រោយពីយល់ឃើញថា "ខ្លឹមសារសំខាន់នៃទឡ្ហីករណ៍ នៅក្នុងសំណើ[សុំផ្អាកដំណើរការនីតិវិធី] គឺផ្តោតលើសិទ្ធិមានមេធាវីតំណាង"[២៦] ហេតុដូច្នេះ អង្គបុរេជំនុំជម្រះនឹងធ្វើការពិនិត្យឱ្យបានពេញលេញលើបញ្ហានានា[២៧] ដែលបានលើកឡើងនៅក្នុងសំណើសុំផ្អាកដំណើរការនីតិវិធី ដើម្បីកំណត់ថាតើករណីនេះទាមទារឱ្យអង្គបុរេជំនុំជម្រះពិចារណា ក្នុងនាមខ្លួនជាតុលាការជាន់ខ្ពស់ដែរ ឬយ៉ាងណា។ អង្គបុរេជំនុំជម្រះយល់ឃើញថា នៅពេលបញ្ហាទាំងនេះបានកើតឡើង បញ្ហានេះស្ថិតនៅក្នុងសមត្ថកិច្ចរបស់សហចៅក្រមស៊ើបអង្កេតនៅឡើយ។ អង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្តីសម្រេចមុនដំបូងនោះ ពុំមានកំហុសអង្គច្បាប់ និងពុំមានភាពអយុត្តិធម៌ឡើយ។ មិនតែប៉ុណ្ណោះ កាលៈទេសៈក៏ពុំមានការផ្លាស់ប្តូរដែលជំរុញឱ្យខ្លួនពិចារណាសេចក្តីសម្រេចឡើងវិញនោះដែរ។ អង្គបុរេជំនុំជម្រះសង្កេតឃើញបន្ថែមទៀតថា ទឡ្ហីករណ៍នៅក្នុងសំណើសុំឱ្យពិចារណាឡើងវិញ គឺទឡ្ហីករណ៍តវ៉ាលើសេចក្តីសម្រេចនេះ និងពុំមានមូលដ្ឋានសំអាងឡើយ។ វាជាការមិនសមហេតុផលឱ្យអង្គបុរេជំនុំជម្រះពិចារណាសេចក្តីសម្រេចនេះឡើងវិញ ជាពិសេសនៅក្នុងកាលៈទេសៈដែលខ្លួនបានសង្កេតឃើញថា ម្ចាស់សំណើដែលពុំមែនជាភាគី និងជាអង្គភាពមួយនៅក្នុងការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក ពុំមានសិទ្ធិធ្វើបណ្តឹង ឬបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះផងនោះ[២៨]។

---

[២៦] សេចក្តីសម្រេច កថាខណ្ឌ ៩។

[២៧] សេចក្តីសម្រេច កថាខណ្ឌ ១០ - ១៣។

[២៨] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Delić រឿងក្តីលេខ IT-04-83-A "សេចក្តីសម្រេចលើញត្តិសុំបន្តកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១០។

០០៣/២៩-០៧-២០១១-អវតក/អបជ (០១)

លេខ/N°: ៥

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទះ**

ច្រានចោលបញ្ញត្តិសុំពិចារណាឡើងវិញ។

**រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២**

**អង្គបុរេជំនុំជម្រះ**

**Rowan DOWNING** **ន៉ីយ ធូល** **Chang-Ho CHUNG** **ហួត វុទ្ធី** **ប្រាក់ គឹមសាន**